# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហព្រះរាជអាជ្ញា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៣

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 06-Jun-2013, 16:00
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ : សាធារណៈ/Public

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអំពីពេលវេលាដែលត្រូវការសម្រាប់សួរសំណួរជនជាប់ចោទ

---

| ដាក់ដោយ៖ | ផ្ញើជូន៖ | ចម្លងជូន៖ |
|---|---|---|
| **សហព្រះរាជអាជ្ញា៖** | **អង្គជំនុំជម្រះសាលាដំបូង៖** | **ជនជាប់ចោទ៖** |
| ជា លាង | ចៅក្រម និល ណុន ជាប្រធាន | នួន ជា |
| **Andrew CAYLEY** | ចៅក្រម Silvia CARTWRIGHT | ខៀវ សំផន |
| | ចៅក្រម យ៉ា សុខន | **មេធាវីការពារក្តី៖** |
| | ចៅក្រមJean-Marc LAVERGNE | សុន អរុណ |
| | ចៅក្រម យូរ ឧត្តរា | Victor KOPPE |

| | |
|---|---|
| **សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖** | គង់ សំអុន |
| | Anta GUISSÉ |
| | Arthur VERCKEN |
| **ពេជ អង្គ** | Jacques VERGÈS |
| **Elisabeth SIMONNEAU FORT** | |

*០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ*

# ចម្លើយតប

1. ក្នុងការឆ្លើយតបទៅនឹងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៣[1] សហព្រះរាជអាជ្ញាស្នើសុំឱ្យ អង្គជំនុំជម្រះសាលាដំបូង ផ្តល់រយៈពេល ០៦ ថ្ងៃពេញដល់សហព្រះរាជអាជ្ញា (ឬ កន្លះៗថ្ងៃ ១២ ដង) ដើម្បីសាកសួរ ខៀវ សំផន និងរយៈពេល ៣ ថ្ងៃពេញ (ឬ កន្លះៗថ្ងៃ ៦ ដង) ដើម្បីសាកសួរ នួន ជា បន្ថែមទៀត។ នេះជាការប៉ាន់ប្រមាណពីពេលវេលាល្អបំផុតដែលស្នើសុំដោយសហព្រះរាជអាជ្ញា ដើម្បីអាចសួរសំណួរទៅកាន់ជនជាប់ចោទឱ្យបានសមស្រប និងច្បាស់លាស់។ ទោះជាយ៉ាងណាក្តី ដោយសារតែចរិកលក្ខណៈនៃសក្ខីកម្មរបស់ជនជាប់ចោទមានការលំបាកក្នុងការព្យាករណ៍ទុកជាមុន ហើយការផ្តល់សក្ខីកម្មទាំងនោះក៏មិនងាយនឹងបង្ហាញចេញដោយងាយដែលនោះ សហព្រះរាជអាជ្ញាស្នើសុំបន្ថែមទៀតឱ្យ អង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតឱ្យបានការបត់បែនខ្លះ ក្នុងការពិចារណាផ្តល់ពេលបន្ថែមដល់ភាគី ប្រសិនបើយល់ថាជាការចាំបាច់ដើម្បីស្វែងរកការពិតចំពោះការចោទប្រកាន់នានាដែលកំពុងលើកយកមកពិភាក្សា ដោយសារបញ្ហានេះជាបេះដូងនៃសវនាការមួយនេះ។

2. ថិរវេលាដែលត្រូវការដើម្បីសាកសួរឱ្យបានពេញលេញដល់ជនជាប់ចោទ ត្រូវបានកំណត់ដោយកត្តាពីរសំខាន់គឺ ចំនួន វិសាលភាព និងភាពស្មុគស្មាញនៃបញ្ហាដែលត្រូវកំណត់នៅក្នុងសវនាការនេះដែលត្រូវបង្ហាញដោយសហព្រះរាជអាជ្ញា និងទីពីរគឺជាការពិតដែលថា ជនជាប់ចោទមិនបានសារភាព ឬទទួលស្គាល់នូវគោលការណ៍នានាដែលត្រូវបានចោទប្រកាន់ មុនពេល ឬក្នុងអំឡុងពេលនៃការជំនុំជម្រះនេះទេ។ តាមការពិត ជនជាប់ចោទទាំងពីរនាក់បានបដិសេដចំពោះការកើតឡើងនៃបទឧក្រិដ្ឋនានាដែលកំពុងលើកយកមកពិភាក្សា និងការទទួលខុសត្រូវផ្លូវច្បាប់នានាចំពោះបទឧក្រិដ្ឋទាំងនោះ។ ពួកគេក៏បានបដិសេធនូវការចោទប្រកាន់មួយចំនួន នៅក្នុងដីកាដំណោះស្រាយដែលជាប់ទាក់ទងនឹងតួនាទី ភារកិច្ចរបស់ពួកគេនៅក្នុងបក្សកម្មុយនីស្តកម្ពុជា (បកក) និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ (DK)។

[1] ការប្រកាសពីសវនាការដែលនៅសេសសល់ មុនពេលបញ្ចប់កិច្ចដំណើរការនីតិវិធីដេញដោលលើភ័ស្តុតាងក្នុងសំណុំរឿង ០០២/០១ និងការកំណត់ការបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការចុងក្រោយសម្រាប់ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣, អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៣ ត្រង់កថាខណ្ឌ ៦។

3. នៅក្នុងសំណុំរឿងនេះ ព្រឹត្តិការណ៍ឧក្រិដ្ឋកម្មចំនួនបីរួមគ្នា បានលើកឡើងនៅដំណាក់កាលដំបូងនៃសំណុំរឿង ដែលបានកើតឡើងនៅក្នុងតំបន់ភូមិសាស្ត្រដ៏ធំមួយ ហើយរួមមានបទឧក្រិដ្ឋជាច្រើនដែលមានការពាក់ព័ន្ធ។ ការជម្លៀសប្រជាជនដោយបង្ខំលើកទីមួយចេញពីក្រុងភ្នំពេញ ទៅកាន់ទីកន្លែងជាច្រើនចាប់ផ្តើមពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ត្រូវបានធ្វើឡើងដោយមានបទឧក្រិដ្ឋមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុកបុកម្នេញ និងអំពើអមនុស្សធម៌ផ្សេងៗទៀត[2]។ ការជម្លៀសប្រជាជនដោយបង្ខំលើកទីពីរ ទៅកាន់ភូមិភាគឧត្តរ និងពាយ័ព្យ បន្តពីខែ កញ្ញា ឆ្នាំ១៩៧៥ រហូតដល់ ឆ្នាំ ១៩៧៦ ហើយជាមួយនឹងបទឧក្រិដ្ឋដូចគ្នាជាច្រើនទៀតដូចជាការបាត់ខ្លួនដោយបង្ខំ[3]។ ការសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃត្រូវបានប្រព្រឹត្តឡើងក្នុងចំនួនដ៏ច្រើនក្នុងអំឡុងពេលក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥[4]។ បទឧក្រិដ្ឋនានាដែលបានចោទប្រកាន់ គឺជាលទ្ធផលនៃគោលនយោបាយនានារបស់ បកក ដែលក្នុងនោះជនជាប់ចោទមានការទទួលខុសត្រូវ រួមទាំងគោលនយោបាយដែលជាប់ទាក់ទងនឹងការជម្លៀសដោយបង្ខំ សហករណ៍ និងការប្រព្រឹត្តចំពោះខ្មាំង។ ដូច្នេះ ការសួរដេញដោលជនជាប់ចោទទៅលើប្រធានបទនិមួយៗទាំងនេះ ពិតជាមានភាពចាំបាច់។

4. ការចូលរួមរបស់ជនជាប់ចោទ និងទំនាក់ទំនងរបស់ពួកគេទៅនឹងអំពើឧក្រិដ្ឋកម្មទាំងនេះ មានភាពស្មុគស្មាញផ្នែកអង្គហេតុ ហើយពួកគេបានជំទាស់ដែរ។ តួនាទីរបស់ពួកគេនៅក្នុង បបក និងនៅក្នុងកម្ពុជាប្រជាធិបតេយ្យ មុនពេល អំឡុងពេល និងក្រោយពេលដែលបទឧក្រិដ្ឋទាំងនេះត្រូវបានប្រព្រឹត្តតម្រូវឱ្យមានការពិនិត្យយ៉ាងល្អិតល្អន់ ដើម្បីកំណត់នូវអត្ថិភាព និងការចូលរួមពីពួកគេនៅក្នុងសហឧក្រិដ្ឋកម្មរួមដែលបានចោទប្រកាន់ ទោះបីពួកគេបានប្រព្រឹត្តបទឧក្រិដ្ឋទាំងនោះ រួមនឹងការចូលរួមតាមមធ្យោបាយផ្សេងទៀតក្តី។ បើទោះជាមិនបានការចោទប្រកាន់ថា ជនជាប់ចោទបានប្រព្រឹត្តអំពើឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ដោយផ្ទាល់ក៏ដោយ ក៏ត្រូវមានការពិនិត្យទៅលើរចនាសម្ព័ន្ធស្ថាប័នដែលជាមធ្យោបាយរបស់ពួកគេក្នុងការប្រព្រឹត្តបទឧក្រិដ្ឋទាំងនោះដែរ ដែលតាមរយៈនោះជនជាប់ចោទ បានអនុវត្តការត្រួតត្រានៅលើព្រឹត្តិការណ៍ទាំងនេះ។ រចនាសម្ព័ន្ធទាំងនេះរួមមាន ស្ថាប័ននយោបាយ រដ្ឋបាល និងយោធា បបក និងកម្ពុជាប្រជាធិបតេយ្យ និងទំនាក់ទំនងរបស់រចនាសម្ព័ន្ធទាំងនេះ

---

2 ឯកសារ **D427** ដីកាដំណោះស្រាយ, ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ត្រង់កថាខណ្ឌ ២២៤ ដល់ ២៦០។

3 ឯកសារ **D427** ដីកាដំណោះស្រាយ, ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ត្រង់កថាខណ្ឌ ២៦២ ដល់ ២៨១។

4 ឯកសារ **D427** ដីកាដំណោះស្រាយ, ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ត្រង់កថាខណ្ឌ ៦៩៨ ដល់ ៧១៤។

ជាមួយជនជាប់ចោទនីមួយៗ។ ជាពិសេស រចនាសម្ព័ន្ធទាំងនេះរួមមានប្រតិបត្តិការរបស់គណៈមជ្ឈិម គណៈអចិន្ត្រៃយ៍ និងមន្ទីរ៨៧០ ក្នុងចំណោមរចនាសម្ព័ន្ធពាក់ព័ន្ធផ្សេងៗទៀត។ ការពិនិត្យលម្អិតទៅលើតួនាទីរបស់ជនជាប់ចោទនៅក្នុងរចនាសម្ព័ន្ធទាំងនេះ ខ្សែរយៈទាក់ទងរវាង និងតាមរយៈរចនាសម្ព័ន្ធទាំងនេះ ដែលគោលនយោបាយឧក្រិដ្ឋត្រូវបានផ្សព្វផ្សាយ តម្រូវឲ្យមានការពិនិត្យឲ្យដ៏ល្អិតល្អន់ និងមានភាពចំបាច់។

5. ដូចដែលបានរៀបរាប់ពីខាងលើ មានពេលវេលាសមស្របសក្នុងការសាកសួរសំណួរទៅជនជាប់ចោទ ដោយសារពួកគេក៏បានជំទាស់ទាំងរឹងទទឹងពីអត្ថិភាពនៃសហឧក្រិដ្ឋកម្មរួម ពីការចូលរួមរបស់ពួកគេនៅក្នុងសហឧក្រិដ្ឋកម្មរួម មុខតំណែង និងអំណាចរបស់ពួកគេ ការចូលរួមរបស់ពួកគេដោយផ្ទាល់ ឬមិនផ្ទាល់នៅក្នុងបទឧក្រិដ្ឋនានាដែលត្រូវបានចោទប្រកាន់ និងការដឹងលឺរបស់ពួកគេអំពីបទឧក្រិដ្ឋនានាដែលបានប្រព្រឹត្តដូចដែលបានចោទប្រកាន់ផងដែរ។ ដោយសារក្នុងសំណុំរឿងនេះ ជំហរទាំងលើអង្គហេតុ និងអង្គច្បាប់របស់អយ្យការ និងមេធាវីការពារ ស្ទើរតែផ្ទុយគ្នាទាំងស្រុងនោះ តម្រូវឲ្យមានការសាកសួរឲ្យបានល្អិតល្អន់ដើម្បីនាំទៅដល់ការស្វែងរកការពិត ។

6. ក្នុងករណីស្រដៀងគ្នានេះ នៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងៗទៀត គេបានផ្តល់ថិរវេលាជាច្រើនសម្រាប់សាកសួរជនជាប់ចោទ ជាពិសេស នៅពេលដែលជនជាប់ចោទមានតួនាទីជាមេដឹកនាំជាន់ខ្ពស់ផ្នែកនយោបាយ ឬយោធា ហើយនៅពេលមានការចោទប្រកាន់ពីការចូលរួមក្នុងការប្រព្រឹត្តរបស់ពួកគេក្នុងឧក្រិដ្ឋកម្មធំៗជាច្រើន ក្នុងអំឡុងពេលដ៏វែងមួយនោះ។ ឧទាហរណ៍ នៅចំពោះមុខតុលាការពិសេសសម្រាប់សៀរ៉ាឡេអូន ក្នុង*រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Charles Ghankay Taylor* នោះ ជនចាប់ចោទTaylor ត្រូវបានតុលាការសាកសួរជាច្រើនខែ។ ការសាកសួរដោយផ្ទាល់ពីមេធាវីការពារក្តីចំណាយពេល១៣សប្តាហ៍[5] និងការសួរដេញដោលដោយអយ្យការចំណាយពេលប្រហែល

[5] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Charles Ghankay Taylor*, សំណុំរឿងលេខ SCSL-2003-01-T, ប្រតិចារឹក (អង្គជំនុំជម្រះសាលាដំបូង II នៃតុលាការ SCSL), ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២00៩ (ភាសាអង់គ្លេស); *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Charles Ghankay Taylor*, សំណុំរឿងលេខ SCSL-2003-01-T, ប្រតិចារឹក (អង្គជំនុំជម្រះសាលាដំបូង II នៃតុលាការ SCSL), ថ្ងៃទី ១0 ខែ វិច្ឆិកា ឆ្នាំ ២00៩ (ភាសាអង់គ្លេស)។

១១ សប្ដាហ៍[6]។ Taylor ជាអតីតប្រធានាធិបតីប្រទេសលីបេរីយ៉ា ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋចំនួន ១១ នៃបទឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលរួមមាន អំពើហិង្សា (ផ្លូវភេទ) ការបំភិតបំភ័យប្រជាជនស៊ីវិល ការចាប់ពង្រត់ និងការងារពលកម្មដោយបង្ខំ។

7. នៅក្នុងរឿងក្ដី *Krajišnik* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានផ្ដល់រយៈពេល ២១ ថ្ងៃ សម្រាប់ការសាកសួរដោយផ្ទាល់ពីមេធាវីការពារក្ដី[7] ជាមួយជនជាប់ចោទ និង រយៈពេល១៥ ថ្ងៃ សម្រាប់ការសួរឆ្លង[8]។ Momčilo Krajišnik ជាសមាជិកម្នាក់នៃថ្នាក់ដឹកនាំបូស្នី-ស៊ែប (ដែលក្រោយមកក្លាយជា “Republika Srpska”) ក្នុងអំឡុងពេលដែលមានជម្លោះប្រដាប់អាវុធដែលបានកើតឡើងនៅបូស្នី ហឺហ្សេហ្គោវីណា នៅចន្លោះឆ្នាំ១៩៩២ ដល់ឆ្នាំ១៩៩៥។ គាត់ជាសមាជិកនៃគណៈកម្មធិការគណបក្សប្រជាធិបតេយ្យស៊ែបនៅបូស្នី និង ហឺហ្សេហ្គោវីណា (SDS) និងជាប្រធានសភាបូស្នី-ស៊ែប។ ក្នុងចំណោមបទឧក្រិដ្ឋផ្សេងៗទៀត គាត់ត្រូវបានចោទប្រកាន់ពីការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ជាតិសាសន៍ ឬសាសនា ការនិរទេស ការជម្លៀសដោយបង្ខំ និងឧក្រិដ្ឋកម្ម

---

[6] *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង* *Charles Ghankay Taylor*, សំណុំរឿងលេខ SCSL-2003-01-T, ប្រតិចារឹក (អង្គជំនុំជម្រះសាលាដំបូង II នៃតុលាការ SCSL), ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ត្រង់ T31553, T31566 (ភាសាអង់គ្លេស); *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង* *Charles Ghankay Taylor*, សំណុំរឿងលេខ SCSL-2003-01-T, ប្រតិចារឹក (អង្គជំនុំជម្រះសាលាដំបូង II នៃតុលាការ SCSL), ថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ២០១០ ត្រង់ T34859-60 (ភាសាអង់គ្លេស)។

[7] *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង* *Momčilo Krajišnik*, សំណុំរឿងលេខ IT-00-39-T, ប្រតិចារឹក (អង្គជំនុំជម្រះសាលាដំបូង I នៃតុលាការ ICTY) ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០៦ ត្រង់ T22980 (ការចាប់ផ្ដើមសាកសួរដោយផ្ទាល់ពីមេធាវីការពារក្ដី) (ភាសាអង់គ្លេស); *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង* *Momčilo Krajišnik*, សំណុំរឿងលេខ IT-00-39-T, ប្រតិចារឹក (អង្គជំនុំជម្រះសាលាដំបូង I នៃតុលាការ ICTY) ថ្ងៃទី ២៥ ឧសភា ឆ្នាំ ២០០៦ ត្រង់ T24799 (បញ្ចប់ការសាកសួរដោយផ្ទាល់ពីមេធាវីការពារក្ដី) (ភាសាអង់គ្លេស)។

[8] *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង* *Momčilo Krajišnik*, សំណុំរឿងលេខ IT-00-39-T, សាលក្រម (អង្គជំនុំជម្រះសាលាដំបូង I នៃតុលាការ ICTY), ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៦ ត្រង់ T24859 (ការចាប់ផ្ដើមសាកសួរឆ្លង) *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង* *Momčilo Krajišnik*, សំណុំរឿងលេខ IT-00-39-T, ប្រតិចារឹក (អង្គជំនុំជម្រះសាលាដំបូង I នៃតុលាការ ICTY) ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៦ក ត្រង់ T25944 (ចុងបញ្ចប់ការសាកសួរឆ្លង)។

ប្រឆាំងមនុស្សជាតិ។ បទឧក្រិដ្ឋទាំងនេះរួមមាន ការផ្លាស់ទីដោយបង្ខំចំពោះជនស៊ីវិលមូស្លីម និងក្រូអាតរាប់ពាន់នាក់[9]។

8. នៅក្នុងសំណុំរឿង *Blaškic,* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានផ្តល់ពេលវេលាចំនួនជាង ១៤ថ្ងៃ សម្រាប់ការសួរសំណួរបឋម[10] និងជាង ១៣ ថ្ងៃសម្រាប់ការសួរឆ្លង[11]។ Tihomir Blaškic គឺជាមេបញ្ជាការក្រុមប្រឹក្សាការពារក្រូអាត ដែលជាទីតាំងយោធាផ្លូវការនៃសហគមន៍ក្រូអាតនៅ Boasnia និង Herzegovina។ នៅក្នុងតួនាទីនោះ គាត់ទទួលខុសត្រូវតំបន់ Lašva Valley ដែលគ្របដណ្តប់ក្រុងចំនួន ៤ នៅ Boasnia កណ្តាល និង Herzegovina។ Blaškic ត្រូវបានចោទប្រកាន់ពីបទល្មើសជាច្រើន រួមទាំងការសម្លាប់ដោយចេតនា និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា[12]។

9. ជនជាប់ចោទទាំងបីរូប គឺ Charles Taylor, Momčilo Krajišnik និង Tihomir Blaškic ទាំងអស់គ្នាបានបដិសេធអំពីការជាប់ពាក់ព័ន្ធនៅក្នុងឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ដូចជនជាប់ចោទនៅក្នុងសំណុំរឿងនេះដែរ។ អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថានៅពេលដែលមានមន្ត្រីជាន់ខ្ពស់ណាមួយ ត្រូវបានចោទប្រកាន់ក្នុងការប្រព្រឹត្តបទល្មើសអន្តរជាតិធ្ងន់ធ្ងរ ដោយសារមន្ត្រីដែលនៅថ្នាក់ក្រោមជាចារី ភាគីមានភារកិច្ចត្រូវសាកសួរ សំណួរទៅជនជាប់ចោទក្នុងរយៈពេលដ៏ច្រើន។

10. ក្នុងករណីដែលជនជាប់ចោទបានបដិសេធការចោទប្រកាន់នានា និងគោលការណ៍អង្គហេតុសំខាន់ៗគាំទ្រការលើកឡើងរបស់ពួកគេ ថិរវេលានៃភាពចាំបាច់សម្រាប់ភាគី ដែលត្រូវសួរសំណួរទៅកាន់

[9] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Momčilo Krajišnik*, សំណុំរឿងលេខ IT-00-39-T, សាលក្រម (អង្គជំនុំជម្រះសាលាដំបូង I នៃតុលាការ ICTY), ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៦ ត្រង់កថាខណ្ឌ ៧២៩, ៧៣១ ដល់ ៧៣២, ៨២៥ (ភាសាអង់គ្លេស)។

[10] *សំណុំរឿង រដ្ឋអាជ្ញា ទល់នឹង Tihomir Blaškic,* លេខសំណុំរឿង IT-95-14-T, ប្រតិចារឹក (អង្គជំនុំជម្រះសាលាដំបូង Iនៃតុលាការ ICTY), ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៩៩ ត្រង់ T22735 បន្ទាត់ទី 7-24 (ភាសាអង់គ្លេស)។

[11] *សំណុំរឿង រដ្ឋអាជ្ញា ទល់នឹង Tihomir Blaškic,* លេខសំណុំរឿង IT-95-14-T, ប្រតិចារឹក (អង្គជំនុំជម្រះសាលាដំបូង I នៃតុលាការ ICTY), ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៩៩ ត្រង់ T22735 បន្ទាត់ទី 7-24 (ភាសាអង់គ្លេស)។

[12] *សំណុំរឿង រដ្ឋអាជ្ញា ទល់នឹង Tihomir Blaškic,* លេខសំណុំរឿង IT-95-14-T, សាលក្រម (អង្គជំនុំជម្រះសាលាដំបូងI នៃតុលាការ ICTY), ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០០០ ត្រង់កថាខណ្ឌ ៧។

ជនជាប់ចោទត្រូវបានផ្តល់ជូនក្នុងរយៈពេលដ៏សមស្របមួយ។ ការណ៍នេះគឺដើម្បីធានាថា មេធាវីការពារក្តីមានឱកាសដើម្បីបំភ្លឺគោលជំហររបស់ខ្លួនក្នុងការការពារ តំណាងអយ្យការមានឱកាសក្នុងការបង្ហាញនូវការចោទប្រកាន់ ហើយដើមបណ្តឹងរដ្ឋប្បវេណីអាចបង្ហាញនូវជំហរនានា របស់ជនរងគ្រោះ។ ដោយហេតុថាជនជាប់ចោទជាមនុស្សសំខាន់សម្រាប់ការចោទប្រកាន់នៅក្នុងសំណុំរឿងនេះ និងស្ថិតនៅក្នុងតួនាទីពិសេសមួយក្នុងការឆ្លើយទៅនឹងការចោទប្រកាន់ទាំងនោះ ពេលវេលាចាំបាច់ដើម្បីសួរសំណួរទៅជនជាប់ចោទគួរត្រូវបាន ពិចារណាដោយឡែកពីពេលវេលាដែលត្រូវបានរៀបចំសម្រាប់សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ផ្សេងទៀត ដែលបានផ្តល់សក្ខីកម្មនៅសវនាការ។

11. បន្ថែមពីលើនេះ ការសួរសំណួរយ៉ាងល្អិតល្អន់ទៅជនជាប់ចោទ មានសារសំខាន់យ៉ាងធំធេងទាំងចំពោះជនរងគ្រោះ និងទាំងចំពោះសាធារៈណជនកម្ពុជាជាទូទៅ។ ជនជាប់ចោទនឹងត្រូវបានសាកសួរដោយភាគីឲ្យពន្យល់ពីការប្រព្រឹត្តដែលបានធ្វើចំពោះជនរងគ្រោះ និងប្រជាជនជាទូទៅដែលការធ្វើបែបនេះបង្ហាញទៅពួកគាត់ដោយផ្ទាល់ថា យុត្តិធម៌កំពុងត្រូវបានមើលឃើញថាត្រូវបានសម្រេចឡើង ហើយជាធម្មតាវាធ្វើឲ្យកិច្ចដំណើរការនីតិវិធីគតិយុត្តិបច្ចេកទេស កាន់តែមានភាពជាក់ស្តែង និងប្រកបដោយអត្ថន័យចំពោះប្រជាជន ដែលបានរងទុក្ខវេទនាពីឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ចំពោះជនជាប់ចោទ។ តាមសម្អាងហេតុដូចដែលបានបញ្ជាក់នៅក្នុងសំណើនេះ សូមអង្គជំនុំជម្រះសម្រេចផ្តល់ជូនពេលវេលាសម្រាប់សួរសំណួរដល់ជនជាប់ចោទដូចដែលសហព្រះរាជអាជ្ញាបានស្នើសុំ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៣ | **លោកស្រី ជា លាង** សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY សហព្រះរាជអាជ្ញា | | [signature] |